អេស៊ីលីដា ACLEDA BANK

# សេចក្តីជូនដំណឹង

## ស្តីពី

## កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២២ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ ជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២** ធនាគារ អេស៊ីលីដា នឹងរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ (“កិច្ចប្រជុំ”) តាមរយៈប្រព័ន្ធ **Video Con-Call** ឬ **អ៊ីម៉ែល** នៅ**ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២** វេលាម៉ោង **១៤:០០រសៀល**។

**របៀបវារៈនៃកិច្ចប្រជុំនេះ ត្រូវបានកំណត់ដូចខាងក្រោម៖**

១. អនុម័តការបែងចែកភាគលាភ (ដែលនឹងត្រូវអនុម័តចុងក្រោយដោយនិយ័តករ) និងរក្សាប្រាក់ចំណេញសុទ្ធប្រចាំឆ្នាំ២០២១ ដែលនៅសល់ក្នុងខ្ទង់ប្រាក់ចំណេញរក្សាទុក;
២. អនុម័តគោលការណ៍ភាគលាភ;
៣. អនុម័តការតែងតាំងសមាជិកក្រុមប្រឹក្សា សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត;
៤. អនុម័តការជ្រើសរើសសវនករឯករាជ្យប្រចាំធនាគារ អេស៊ីលីដា សម្រាប់ឆ្នាំហិរញ្ញវត្ថុ២០២៣;
៥. អនុម័តការដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំសម្រាប់ប្រធានក្រុមប្រឹក្សាភិបាល;
៦. អនុម័តការដំឡើងកម្រៃសេវាសម្រាប់ក្រុមប្រឹក្សាភិបាល ២,៩% ស្របតាមអត្រាអតិផរណាឆ្នាំ២០២១; និង
៧. អនុម័តកាលបរិច្ឆេទកំណត់ទុកសម្រាប់ភាគហ៊ុនិក ដែលត្រូវទទួលបានភាគលាភ។

### ដំណើរការនៃកិច្ចប្រជុំ

**មុនពេលកិច្ចប្រជុំ**

| ឯកសារ | ជំហាន-១ | ជំហាន-២ | ជំហាន-៣ | កាលបរិច្ឆេទផ្ញើ (ម៉ោងនៅភ្នំពេញ) | |
|---|---|---|---|---|---|
| | | | | ចាប់ពី | ដល់ |
| ១. លិខិតអញ្ជើញ | ✓ | | | ១-មេសា-២០២២ | ៨-មេសា-២០២២ |
| ២. លិខិតប្រគល់សិទ្ធិ | ✓ | | | | |
| ៣. ការបញ្ជាក់ពីការចូលរួមក្នុងកិច្ចប្រជុំតាមរយៈភ្នាក់ងារ RTP (*) | ✓ | | | | |
| ៤. តំណភ្ជាប់សម្រាប់ការចុះឈ្មោះតាមអនឡាញដើម្បីចូលរួមកិច្ចប្រជុំ (**) | | ✓ | | ៨-មេសា-២០២២ | ១១-មេសា-២០២២ |
| ៥. ឯកសារគាំទ្រ | | ✓ | | | |
| ៦. សេចក្តីណែនាំអំពីការបោះឆ្នោត | | ✓ | | | |
| ៧. តំណភ្ជាប់សម្រាប់ការចូលរួមកិច្ចប្រជុំ (***) | | | ✓ | ២៧-មេសា-២០២២ | ២៩-មេសា-២០២២ |
| ៨. ឃ្លអរកូដសម្រាប់ការបោះឆ្នោត (****) | | | ✓ | | |

**ជំហាន-១៖** ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីភាគហ៊ុនិកនៅកាលបរិច្ឆេទកំណត់ទុក**ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២** នឹងទទួលបានឯកសារក្នុងបញ្ជី**លេខ១** ដល់**លេខ៣** តាមរយៈអ៊ីម៉ែល។ ករណីដែលភាគហ៊ុនិករូបណាពុំអាចចូលរួម និងបោះឆ្នោតតាមកាលបរិច្ឆេទ និងពេលវេលាកំណត់ ភាគហ៊ុនិករូបនោះអាចចាត់បុគ្គលណាម្នាក់ធ្វើជាតំណាងខ្លួន ដើម្បីចូលរួម និងបោះឆ្នោត។ ភាគហ៊ុនិកត្រូវបញ្ជាក់ពីការចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន **(*)** ដោយខ្លួនឯងផ្ទាល់ ឬអ្នកទទួលសិទ្ធិរបស់ខ្លួន និងត្រូវផ្ញើត្រឡប់មកវិញនូវ**លិខិតប្រគល់សិទ្ធិ** ទៅ


អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

**ភ្នាក់ងារ RTP** តាមរយៈមធ្យោបាយអេឡិចត្រូនិក ចាប់ពី **ថ្ងៃទី១ ខែមេសា ឆ្នាំ២០២២** ដល់**ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២** យ៉ាងយូរបំផុត នៅត្រឹម**ម៉ោង១២:០០ថ្ងៃត្រង់**។

**ជំហាន-២៖ ភ្នាក់ងារ RTP** នឹងផ្ញើឯកសារ ដែលមានក្នុងបញ្ជី**លេខ៤** ដល់**លេខ៦** តាមរយៈអ៊ីម៉ែល ជូនដល់ភាគហ៊ុនិក ដែលបានបំពេញ **(*) តែប៉ុណ្ណោះ**។ ភាគហ៊ុនិកត្រូវចុះឈ្មោះ សម្រាប់ការចូលរួមកិច្ចប្រជុំចាប់ពី**ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២** ដល់**ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២**។

**ជំហាន-៣៖** ចាប់ពី**ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២** ដល់**ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ ភ្នាក់ងារ RTP** នឹងផ្ញើឯកសារក្នុងបញ្ជី**លេខ៧** ដល់**លេខ៨** តាមរយៈអ៊ីម៉ែល ជូនដល់ភាគហ៊ុនិក និងអ្នកទទួលសិទ្ធិ ដែលបានបំពេញ **(**)** តែប៉ុណ្ណោះ។

**កំលុងពេលកិច្ចប្រជុំ**

- ភាគហ៊ុនិក និងអ្នកទទួលសិទ្ធិម្នាក់ៗ អាចចូលរួមកិច្ចប្រជុំយ៉ាងហោច **១៥នាទីមុនពេលកិច្ចប្រជុំចាប់ផ្តើម** តាមរយៈតំណភ្ជាប់ ដែលនឹងត្រូវផ្ញើជូនដោយ **ភ្នាក់ងារ RTP** របស់ធនាគារ អេស៊ីលីដា **(***)**។
- ភាគហ៊ុនិក និងអ្នកទទួលសិទ្ធិម្នាក់ៗ ត្រូវបោះឆ្នោតតាមរបៀបវារៈនីមួយៗ នៃកិច្ចប្រជុំ បន្ទាប់ពីការប្រកាសរបស់ប្រធានអង្គប្រជុំ តាមរបៀបវារៈនីមួយៗ។

**សម្គាល់៖**

- *ភាគហ៊ុនិក និង/ឬអ្នកទទួលសិទ្ធិ ដែលពុំបានចុះឈ្មោះចូលរួមកិច្ចប្រជុំតាមរយៈតំណភ្ជាប់ ដែលបានផ្ញើជូនដោយ **ភ្នាក់ងារ RTP** របស់ធនាគារ អេស៊ីលីដា **(**)** តាមកាលកំណត់ខាងលើ នឹងពុំមានសិទ្ធិចូលរួម និងបោះឆ្នោតក្នុងកិច្ចប្រជុំនេះទេ។*
- *ធនាគារ អេស៊ីលីដា សូមរក្សាសិទ្ធិផ្លាស់ប្តូររបៀបនៃកិច្ចប្រជុំ តាមករណីចាំបាច់ ដោយធ្វើការជូនដំណឹងជាមុន។*

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកផ្នែកប្រតិបត្តិការបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (**ភ្នាក់ងារ RTP**) ដូចខាងក្រោម៖

- **លោក លីម អាន** ប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៦០០ ៧៤៣
  - អ៊ីម៉ែល: lim.an@acledabank.com.kh
- **លោក ហួត សុភី** អនុប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល: huot.sophy@acledabank.com.kh
- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ** បុគ្គលិកផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
  - អ៊ីម៉ែល: op.rtp@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**